ព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋាន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
## ស្តីពី
## ការប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែកក្កដា និងទិសដៅការងារសម្រាប់ខែសីហា ឆ្នាំ២០២០ របស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

នាព្រឹកថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោង៨: ០០ នាទី នៅសាលសិក្ខាសាលាខាងជើង បានបើកកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែកក្កដា និងទិសដៅការងារសម្រាប់ខែសីហា ឆ្នាំ២០២០ ក្រោមអធិបតីភាព **ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា** ដោយមានការអញ្ជើញចូលរួមពីឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលមានតួនាទីចាប់ពីប្រធាននាយកដ្ឋានឡើងចំនួន៤៦ នាក់។

ជាកិច្ចចាប់ផ្តើម **ឯកឧត្តមអគ្គលេខាធិការ** បានសម្តែងនូវកិច្ចស្វាគមន៍ចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលមានវត្តមានក្នុងអង្គប្រជុំ និងបានអនុញ្ញាតឱ្យឯកឧត្តម លោកជំទាវ ជាអគ្គនាយក អគ្គនាយិកា និងលោកជំទាវអគ្គាធិការ រាយការណ៍អំពីលទ្ធផលការងារសម្រេចបានក្នុងខែកក្កដា និងទិសដៅការងារខែសីហា ឆ្នាំ២០២០ ជូនអង្គប្រជុំជ្រាប។

បន្ទាប់ពីស្តាប់សេចក្តីរាយការណ៍របស់ឯកឧត្តម និងលោកជំទាវរួចមក **ឯកឧត្តមអគ្គលេខាធិការ** បានណែនាំឱ្យគ្រប់អង្គភាពបន្តការខិតខំបន្ថែមទៀតប្រកបដោយភាពវៃឆ្លាតក្នុងការស្វែងរកដៃគូអភិវឌ្ឍនានា ដើម្បីបំពេញបន្ថែមលើចំណុចខ្វះខាត ពិសេសនាយកដ្ឋានព័ត៌មានវិទ្យា នាយកដ្ឋានស្រាវជ្រាវកិច្ចការអន្តរជាតិ នាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស ត្រូវបន្តធ្វើការងារជាមួយដៃគូអភិវឌ្ឍរបស់ខ្លួន (វិទ្យាស្ថានអាស៊ី វិទ្យាស្ថានការទូតនៃក្រសួងការបរទេស ក្រុមហ៊ុន Huawei និងដៃគូបណ្តុះបណ្តាលនានា...។ល។ ) ដើម្បីឈានដល់ការចុះកិច្ចព្រមព្រៀង។

**ឯកឧត្តមអគ្គលេខាធិការ** ក៏បានស្នើឱ្យគ្រប់អគ្គនាយកដ្ឋាន នាយកដ្ឋាន ជួយណែនាំមន្ត្រីឱ្យមានការប្រុងប្រយ័ត្ន និងការពារខ្លួនកុំឱ្យឆ្លងជំងឺកូវីដ១៩ (Covid-19) ក្នុងអំឡុងពេល



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh

ឈប់សម្រាកពីថ្ងៃទី១៧ដល់២១ ខែសីហា ឆ្នាំ២០២០ ហើយពេលចូលមកធ្វើការវិញត្រូវពាក់ម៉ាស់រយៈពេល១៤ថ្ងៃ និងសូមឱ្យមន្ត្រីទាំងអស់គ្នាចូលរួមយកចិត្តទុកថែរក្សាទ្រព្យសម្បត្តិរដ្ឋ ការសន្សំសំចៃ ទឹក ភ្លើង ពេលចេញពីធ្វើការត្រូវចាក់សោរទ្វារអគារ។

ជាកិច្ចបន្ទាប់ **ឯកឧត្តមអគ្គលេខាធិការ** បានបង្ហាញជូនអំពីការវិវឌ្ឍនៃព្រឹត្តិការណ៍ជាតិ តំបន់ និងពិភពលោក ជូនអង្គប្រជុំជ្រាប ដើម្បីជាចំណេះដឹងទូទៅក្នុងការប្រតិបត្តិការការងារប្រចាំថ្ងៃឱ្យកាន់តែល្អប្រសើរ និងបានជម្រាបជូនលទ្ធផលការងារដែលសម្រេចបានដូចខាងក្រោម ៖

## I.លទ្ធផលការងារសម្រេចបាន

### ១-មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយ

-គណៈកម្មការទី៧ បានអញ្ជើញជួបពិភាក្សាការងារជាមួយប្រធានមន្ទីរទេសចរណ៍រាជធានីភ្នំពេញ និងអគ្គនាយកលំនៅដ្ឋាននៃក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ នៅទីស្តីការក្រសួង

-ក្រុមសមាជិកភូមិភាគទី១ បានអញ្ជើញចុះស្រាវជ្រាវ និងប្រមូលព័ត៌មាន ដើម្បីត្រៀមរៀបចំវេទិកាភូមិភាគទី១ នាពេលខាងមុខ នៅសង្កាត់ក្រាំងធ្នង់ រាជធានីភ្នំពេញ។

### ២-មុខងារតំណាង

-សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា បានអញ្ជើញជួបសំណេះសំណាល និងចូលរួមក្នុងពិធីផ្សេងៗរួមមាន៖

+ចូលរួមគោរពវិញ្ញាណក្ខន្ធ និងរំលែកទុក្ខជាមួយក្រុមគ្រួសារសពឯកឧត្តមព្រឹទ្ធាចារ្យ **រួន សិង្ហផាន់** អនុប្រធានគណៈកម្មាធិការគណបក្សខេត្តកោះកុង និងសពលោកឧត្តមសេនីយ៍ត្រី **អ៊ុក សាម៉ុន** មេបញ្ជាការកងរាជអាវុធហត្ថ ខេត្តពោធិ៍សាត់

+ជួបសំណេះសំណាល សួរសុខទុក្ខប្រជាពលរដ្ឋ មន្ត្រី និងអាជ្ញាធរមូលដ្ឋាន នៅសង្កាត់បឹងកក់ទី២ ខណ្ឌទួលគោក និងសង្កាត់អូរឬស្សី ខណ្ឌ៧មករា រាជធានីភ្នំពេញ

-សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា និងឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ស៊ឹម កា** អនុប្រធានទី១ព្រឹទ្ធសភា បានអញ្ជើញចុះពិនិត្យការងារគ្រប់គ្រង អភិរក្សសារមន្ទីរ២ធ្នូ នៅស្រុកស្នួល ខេត្តក្រចេះ

-ឯកឧត្តមកត្តិសង្គហបណ្ឌិត **ទេព ងន** អនុប្រធានទី២ ព្រឹទ្ធសភា បានអញ្ជើញនាំយកទានព្រះវស្សា និងទេយ្យទាន ព្រមទាំងបច្ច័យសម្រាប់កសាងវត្តអូរសោម នៅខេត្តពោធិ៍សាត់

-ឯកឧត្តមប្រធានគណៈកម្មការទី១ បានអញ្ជើញទទួលអំណោយរបស់សម្តេចប្រធានព្រឹទ្ធសភា (កុំព្យូទ័រចំនួន១០គ្រឿង និងម៉ាស៊ីនព្រីនធ័រចំនួន៥គ្រឿង) ដើម្បីប្រគល់ជូនវិទ្យាល័យសៀមប៉ាង នៅខេត្តស្ទឹងត្រែង

-លោកជំទាវប្រធានគណៈកម្មការទី៨ បានអញ្ជើញនាំយកអំណោយ និងថវិការបស់សម្តេចប្រធានព្រឹទ្ធសភា ទៅចែកជូនកុមារកំព្រា នៅមណ្ឌលកុមារភូមិខែ ខេត្តកំពង់ស្ពឺ

-សមាជិកព្រឹទ្ធសភា បានអញ្ជើញជួបសំណេះសំណាលជាមួយប្រជាពលរដ្ឋ និងពិភាក្សាការងារជាមួយអាជ្ញាធរមូលដ្ឋាន ក្រុមប្រឹក្សាឃុំ សង្កាត់ និងនាំយកទៀនព្រះវស្សា ទេយ្យទាន និងបច្ច័យ ប្រគេនដល់ព្រះសង្ឃដែលគង់ចាំព្រះវស្សានៅវត្តនានា និងចូលរួមរំលែកទុក្ខដល់ក្រុមគ្រួសារសព ព្រមទាំងចូលរួមពិធីផ្សេងៗ នៅរាជធានីភ្នំពេញ ខេត្តកណ្តាល កំពង់ស្ពឺ ព្រៃវែង កំពង់ចាម ត្បូងឃ្មុំ តាកែវ កំពត កែប កោះកុង កំពង់ឆ្នាំង ពោធិ៍សាត់ កំពង់ធំ ក្រចេះ មណ្ឌលគិរី បាត់ដំបង បន្ទាយមានជ័យ ឧត្តរមានជ័យ សៀមរាប ស្ទឹងត្រែង និងខេត្តរតនគិរី

-ក្រុមសមាជិកភូមិភាគទី១ បានអញ្ជើញចុះរៀបចំវេទិកាសាធារណៈ ដើម្បីផ្សព្វផ្សាយលទ្ធផលការងារ និងដោះស្រាយបញ្ហាប្រឈមនានា នៅរាជធានីភ្នំពេញ

-ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញជួបសំណេះសំណាល សួរសុខទុក្ខ និងនាំយកអំណោយមនុស្សធម៌ទៅប្រគល់ជូនអាជ្ញាធរសង្កាត់ព្រែកលៀប សង្កាត់ព្រែកតាសេក និងសង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ដើម្បីរួមចំណែកក្នុងការបង្ការ និងទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ១៩ ។

## ៣-មុខងារសហប្រតិបត្តិការអន្តរជាតិ

-ឯកឧត្តមអនុប្រធានគណៈកម្មការទី១ បានចូលរួមប្រជុំស្តីពីការផ្ទុះឡើងនៃជំងឺកូវីដ១៩ របស់មហាសន្និបាតសភាតំបន់អាស៊ី ( APA) តាមរយៈវីដេអូ Conference

-លោកជំទាវប្រធានគណៈកម្មការទី៥ បានទទួលជួបពិភាក្សាការងារជាមួយលោកស្រីនាយកគ្រប់គ្រងទូទៅ Cambodia TV Co.,Ltd

-ឯកឧត្តមអនុប្រធានគណៈកម្មការទី៧ បានចូលរួមប្រជុំស្តីពី ផលប៉ះពាល់ការអប់រំ និងវប្បធម៌នៃការរីករាលដាលជំងឺកូវីដ១៩ ក្នុងក្របខ័ណ្ឌ (APF) តាមរយៈវីដេអូ Conference

-ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា បានទទួលជួបពិភាក្សាការងារជាមួយអ្នកពិគ្រោះយោបល់

និងមន្ត្រីសម្របសម្រួលក្រុមការងាររបស់វិទ្យាស្ថានសភាកម្ពុជា(PIC) ស្តីពី ការសិក្សាវាយតម្លៃពីតម្រូវការសភា នៅសាលប្រជុំពិសេស។

**៤-មុខងារអភិវឌ្ឍន៍ស្ថាប័ន**

-បន្តយកចិត្តទុកដាក់ចូលរួមយុទ្ធនាការប្រយុទ្ធប្រឆាំងជំងឺកូវីដ១៩ (Covid-19)

-បន្តយកចិត្តទុកដាក់ការងារអនាម័យ បរិស្ថាន សំរាម សួនច្បារ និងការដាំដើមឈើ ប្រព័ន្ធទឹក លូ ថ្នល់ និងចំណតរថយន្ត ដើម្បីធានាឱ្យមានផាសុកភាព និងបរិស្ថានបៃតង

-ការបង្កើយគម្រោងជួសជុល និងកែលម្អអគារមួយចំនួន ការងារសន្តិសុខ និងសណ្តាប់ធ្នាប់

-បានផ្ទេរ និងប្រគល់អគារមួយខ្នងជូនឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដើម្បីប្រតិបត្តិការងារជាប្រចាំ

-បន្តអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន រដ្ឋបាលអេឡិចត្រូនិច ការប្រើប្រាស់ Zoom ប្រព័ន្ធសំឡេង ការផ្សព្វផ្សាយតាមបណ្តាញសង្គម បណ្ណាល័យ បណ្ណសារដ្ឋានអេឡិចត្រូនិច ការងារព័ត៌មាន ការផលិតខ្សែវីដេអូ និងការបោះពុម្ព

-បន្តយកចិត្តទុកដាក់មជ្ឈដ្ឋានដែលនៅខ្សោយ និងសមត្ថភាព ផលិតសេវានៅទាប

-ការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការ ៖ ចំណេះដឹង ជំនាញ ភាសា គ្រប់គ្រង ដឹកនាំ/បច្ចេកវិទ្យាព័ត៌មាន

-សិក្សាការរៀបចំ( PCA) ដំណាក់កាលបន្ទាប់ពី( PIC )ការរៀបចំ Legal Database របស់ព្រឹទ្ធសភា

-សិក្សា និងធ្វើបច្ចុប្បន្នភាពគោលការណ៍ និងគោលនយោបាយនានាឱ្យបានសមស្រប នឹងដំណាក់កាលថ្មី

-ការបង្កើន 3E's ដោយយកការសន្សំសំចៃ និងវិចារណកម្មថវិកាជាស្នូល ដើម្បីទ្រទ្រង់ដំណើរការថវិការហូតដល់ចុងឆ្នាំ២០២០

-បានប្រជុំពិនិត្យ និងពិភាក្សាស្តីពី រចនាសម្ព័ន្ធ តួនាទី ភារកិច្ច ការងារចាត់តាំង និងផែនការយុទ្ធសាស្ត្ររយៈពេល១០ឆ្នាំ (២០២១-២០៣០) របស់អគ្គនាយកដ្ឋានទាំង៥

-បានប្រជុំត្រួតពិនិត្យ និងវាយតម្លៃលើរបាយការណ៍វឌ្ឍនភាព សមិទ្ធកម្ម ផែនការសកម្មភាព (MAP3) និងសូចនាករសមិទ្ធកម្ម (KPIS)ប្រចាំត្រីមាសទី២ ឆ្នាំ២០២០ របស់អគ្គលេខាធិការ-ដ្ឋានព្រឹទ្ធសភា

-បានប្រជុំពិនិត្យ និងពិភាក្សាលើផែនការយុទ្ធសាស្ត្រថវិកា៣ឆ្នាំរំកិល (២០២១-២០២៣)

និងគម្រោងថវិការបស់ព្រឹទ្ធសភាឆ្នាំ២០២១

-បានប្រជុំពិភាក្សាការងារជាមួយថ្នាក់ដឹកនាំអគ្គនាយកដ្ឋានសេវាច្បាប់ និងសមូហភាពដែនដី និងលេខាធិការដ្ឋានអមគណៈកម្មការទាំង១០

-បានប្រជុំក្រុមប្រឹក្សាវិន័យនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-បានប្រជុំបូកសរុបលទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប្រចាំឆមាសទី១ និងលើកទិសដៅការងារឆមាសទី២ ឆ្នាំ២០២០។

**៥-ការបណ្តុះបណ្តាលធនធានមនុស្ស**

-បានបើកវគ្គបណ្តុះបណ្តាលក្នុងប្រទេសចំនួន០២វគ្គ មានសិក្ខាកាមចំនួន៦៩នាក់ ។

II.**ទិសដៅការងារសម្រាប់ខែសីហា ឆ្នាំ២០២០**

*ដំណើរឆ្ពោះទៅកាន់មូលដ្ឋានរបស់ព្រឹទ្ធសភា ក្នុងរយៈពេលវិស្សមកាលចាប់ពីថ្ងៃទី២២ ខែកក្កដា ដល់ថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២០*

-ត្រៀមផ្តល់សេវាជូនសមាជិកព្រឹទ្ធសភា ឱ្យបានល្អប្រសើរ និងគ្រប់ជ្រុងជ្រោយក្នុងដំណើរចុះទៅមូលដ្ឋាន និងជួបសវនាការជាមួយក្រសួងស្ថាប័ននានា

-ត្រៀមសហការធ្វើរបាយការណ៍ចន្លោះសម័យប្រជុំលើកទី៥ និងទី៦ ឱ្យបានទាន់ពេល-វេលា និងល្អប្រសើរ ។

**១-សេវាទ្រទ្រង់មុខងារនីតិកម្ម ៖**

-ត្រៀមរៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងសម័យប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិ-កាលទី៤ ដើម្បីពិនិត្យ និងឱ្យយោបល់លើ៖

១-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពី ការលុបបំបាត់ការយកពន្ធត្រួតគ្នាពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល និងការបង្ការគេចវេះពន្ធ និងការចៀសវាងពន្ធរវាងព្រះរាជាណាចក្រកម្ពុជា និងម៉ាឡេស៊ី

២-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពី ការលុបបំបាត់ការយកពន្ធត្រួតគ្នាពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល និងការបង្ការគេចវេះពន្ធ និងការចៀសវាងពន្ធរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋកូរ៉េ

៣-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងលើសន្ធិសញ្ញាស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌរវាងព្រះរាជាណាចក្រ

កម្ពុជា និងសាធារណរដ្ឋកូរ៉េ

៤-សេចក្តីព្រាងច្បាប់ស្តីពី ការគ្រប់គ្រងការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ

៥-សេចក្តីព្រាងច្បាប់ស្តីពី ការគ្រប់គ្រងល្បែងពាណិជ្ជកម្ម

៦-សេចក្តីព្រាងច្បាប់ស្តីពី វិសោធនកម្ម មាត្រា៣ មាត្រា១៧ មាត្រា២០ មាត្រា២១ មាត្រា២៧ មាត្រា២៨ មាត្រា២៩ មាត្រា៥៤ មាត្រា៥៥ មាត្រា៥៩ នៃច្បាប់ស្តីពីសហជីព

៧-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពី ផលស្តុកត្រីផ្លាស់ទីមធ្យម និងផលស្តុកត្រីផ្លាស់ទីឆ្ងាយនៃអង្គការសហប្រជាជាតិ ។

**២-សេវាទទួលមុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយ៖**

-ត្រៀមសហការ និងសម្របសម្រួលការងារជូនគណៈកម្មការជំនាញជួបសវនាការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធនានា និងការចុះបេសកកម្មនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តក្រុងនានា៖

+គណៈកម្មការទី៣ ទី៨ និងទី១០ អញ្ជើញចុះបេសកកម្មទៅខេត្តព្រះសីហនុ ខេត្តក្រចេះ និងខេត្តស្ទឹងត្រែង។

**៣-សេវាទទួលមុខងារតំណាង៖**

-ត្រៀមរៀបចំជូនថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា ចូលរួមក្នុងពិធីផ្លូវការផ្សេងៗ និងបេសកកម្មនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តក្រុងនានា ៖

+ក្រុមភូមិភាគទី២ ចុះរៀបចំវេទិកាថ្នាក់ស្រុក នៅខេត្តត្បូងឃ្មុំ ។

**៤-កិច្ចសហប្រតិបត្តិការអន្តរជាតិ៖**

-ត្រៀមរៀបចំពិធីជំនួបផ្លូវការរវាងថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា ជាមួយគណៈប្រតិភូជាតិ និងអន្តរជាតិនានា

-ត្រៀមរៀបចំកិច្ចប្រជុំជូនក្រុមយន្តការនានារបស់ព្រឹទ្ធសភាតាមរយៈ Video Conference

-បន្តសកម្មភាពសហប្រតិបត្តិការជាមួយដៃគូនានា ដើម្បីអនុវត្តយុទ្ធសាស្ត្រថវិកាតិចសកម្មភាពច្រើន ។

**៥-ការអភិវឌ្ឍស្ថាប័ន៖**

-នាយកដ្ឋានព័ត៌មានវិទ្យា នាយកដ្ឋានទំនាក់ទំនងអន្តរជាតិ នាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស ត្រូវបន្តទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍន៍របស់ខ្លួន (Huawei, វិទ្យាស្ថានការទូត,

និងដៃគូបណ្តុះបណ្តាលនានា។ល។)

-រៀបចំរបាយការណ៍ចំណូល និងចំណាយថវិកាព្រឹទ្ធសភា ប្រចាំឆមាសទី២ និងប្រចាំឆ្នាំ ២០២០ ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា

-ការពារគម្រោងថវិកាព្រឹទ្ធសភាឆ្នាំ២០២១ កម្រិតនយោបាយជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ត្រៀមរៀបចំបែងចែកកញ្ចប់ថវិកាព្រឹទ្ធសភាឆ្នាំ២០២១ កម្រិតរចនាសម្ព័ន្ធនយោបាយ និងរដ្ឋបាល

-ត្រៀមរៀបចំថវិកាតាមកម្មវិធីឆ្នាំ២០២១ របស់អគ្គនាយកដ្ឋានទាំង៥

-រៀបចំធ្វើបច្ចុប្បន្នភាពគោលការណ៍ហិរញ្ញវត្ថុសំខាន់ៗ និងថវិកាតាមកម្មវិធី លើមូលដ្ឋានរចនាសម្ព័ន្ធថ្មី របស់អគ្គនាយកដ្ឋានទាំង៥

-អគ្គនាយកដ្ឋាន នាយកដ្ឋាន និងគ្រប់អង្គភាពចំណុះទាំងអស់ត្រូវបង្កើន និងពង្រឹងយន្តការការងារតាមប្រព័ន្ធ Online ដើម្បីជានាគុណភាព ប្រសិទ្ធភាព ប្រសិទ្ធផល និងស័ក្តិសិទ្ធិភាពជូនស្ថាប័នឱ្យបានល្អប្រសើរ

-បង្កើនការគ្រប់គ្រងអគារ សារពើភ័ណ្ឌ និងការគ្រប់គ្រងសន្តិសុខ សណ្តាប់ធ្នាប់ អនាម័យ ការសន្សំសំចៃទឹក ភ្លើង ការគ្រប់គ្រង និងការប្រើប្រាស់ INTERNET

-បន្តថែរក្សាហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថាននៅក្នុងព្រឹទ្ធសភា

-រៀបចំប្រព័ន្ធ Website/Webpage ក្នុងកម្រិតអគ្គនាយកដ្ឋាន គណៈកម្មការ និងក្រុមនានា

-បន្តកសាងប្រព័ន្ធគ្រប់គ្រងទិន្នន័យ គ្រប់គ្រងព័ត៌មាន គ្រប់គ្រងរដ្ឋបាល កម្មវិធី Eបណ្ណាល័យ និងEបណ្ណសារ

-បន្តកសាង និងធ្វើបច្ចុប្បន្នភាពគោលការណ៍ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត បម្រើឱ្យការគ្រប់គ្រងក្នុងបរិបទកំណែទម្រង់រដ្ឋបាលសាធារណៈ និងហិរញ្ញវត្ថុសាធារណៈ

-ត្រៀមធ្វើជំរឿនសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ ធនធានមនុស្ស និងតម្រូវការផ្សេងៗ

-បន្តសហការជាមួយក្រុមការងារ FMIS របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ការប្រើប្រាស់ និងបំពាក់សម្ភារៈប្រជុំតាមវីដេអូ Conference

-បញ្ចប់ការងារពិនិត្យ និងសម្រេចលើការរៀបចំរចនាសម្ព័ន្ធ ការងាររចាត់តាំង ផែនការយុទ្ធសាស្ត្ររយៈពេល១០ឆ្នាំ (២០២១-២០៣០) របស់អគ្គនាយកដ្ឋានទាំង៥ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍ ICT អភិវឌ្ឍធនធានមនុស្ស ព័ត៌មាន និងទំនាក់ទំនងសាធារណៈ ការស្រាវជ្រាវ និងសហប្រតិបត្តិការអន្តរជាតិ

-បន្តប្រជុំគណៈកម្មការគោលការណ៍ គោលនយោបាយនានារបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-បង្កើនការបញ្ចូលប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្នុងគ្រប់វិស័យនៃការងាររបស់ស្ថាប័ន។

## សេចក្ដីសន្និដ្ឋាន

ក្នុងខែកក្កដានេះ ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានខិតខំប្រឹងប្រែងយកចិត្តទុកដាក់ក្នុងការផ្ដល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា បំពេញមុខងាររបស់ខ្លួនបានយ៉ាងល្អប្រសើរតាមតម្រូវការចាំបាច់ជាក់ស្ដែង ប្រកបដោយភាពទទួលខុសត្រូវតាមមុខសញ្ញារៀងៗខ្លួន។ ជាពិសេសបានផ្ដល់សេវាជូនសមាជិកព្រឹទ្ធសភា ដើម្បីចុះបំពេញការងារលើមុខងារតាមដានការអនុវត្តច្បាប់ និងមុខងារតំណាង ក្នុងអំឡុងពេលព្រឹទ្ធសភាស្ថិតក្នុងវិស្សមកាល។ ទន្ទឹមនឹងការងារដែលកំពុងតែមមាញឹកនេះដែរ អគ្គ-លេខាធិការដ្ឋាននៅតែបន្តខិតខំពង្រឹងសមត្ថភាពមន្ត្រីរាជការឱ្យកាន់តែមានគុណភាព ដើម្បីផ្ដល់ភាពស័ក្ដិសិទ្ធិក្នុងការផ្ដល់សេវាជូនថ្នាក់ដឹកនាំឱ្យកាន់តែល្អជាលំដាប់តាមរយៈការកែសម្រួលផែនការយុទ្ធសាស្ត្រ រចនាសម្ព័ន្ធ និងការងាររចាត់តាំង របស់អគ្គនាយកដ្ឋានទាំង៥ ឱ្យស្របតាម គោលការណ៍កំណែទម្រង់ និងស្ថានភាពជាក់ស្ដែងរបស់ស្ថាប័ន។ ចំពោះមុខងារអភិវឌ្ឍន៍ស្ថាប័ន បានបន្តលើកកម្ពស់ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន ប្រកបដោយសុវត្ថិភាព។ រដ្ឋបាលអេឡិចត្រូនិច និង Video Conference បានក្លាយជាការពិតនៅក្នុងជីវិតការងារថ្មី សម្រាប់សមាជិកព្រឹទ្ធសភាក្នុងការងារប្រចាំថ្ងៃ និងការងារទំនាក់ទំនងជាមួយតំបន់ និងពិភពលោក។

មន្ត្រីរាជការទាំងអស់ ត្រូវបន្តយកចិត្តទុកដាក់ចូលរួមប្រយុទ្ធប្រឆាំងនឹងការរីករាលដាលនៃជំងឺកូវីដ១៩ (Covid-19) ដែលកំពុងរាលដាលនាពេលបច្ចុប្បន្ន ហើយពុំទាន់មានសញ្ញាថាថមថយនៅឡើយ។

ការអនុវត្តថវិកាចុងឆ្នាំ២០២០ តាមរយៈគោលការណ៍ 3Es ត្រូវតែសកម្មចូលរួមអនុវត្ត និងខិតខំជំនះលើការលំបាកនានា តាមរយៈការស្វែងរកជំនួយពីប្រភពខាងក្រៅដើម្បីបំពេញបន្ថែម។

អង្គប្រជុំបានបញ្ចប់នៅវេលាម៉ោង១០.៣០ នាទីព្រឹក ក្រោមបរិយាកាសរីករាយ ស្និទ្ធស្នាល ប្រកបដោយស្មារតីទទួលខុសត្រូវ។

ថ្ងៃសុក្រ ៣រោច ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២០

ប្រធាននាយកដ្ឋាន

ឡាំង ថន

បានឃើញ និងឯកភាព

អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ

ឈឹម ព្រះខ័ន

បានឃើញ និងឯកភាព

អគ្គលេខាធិការ

អ៊ុំ_សារឹទ្ធ